ក្រសួងទេសចរណ៍
លេខ ០៤១ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦

# ប្រកាស
## ស្តីពី
## ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ចនិងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០២ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៤ ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច



អគារលេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website:www.mot.kh

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._**

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធានក្នុងការគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២._**

ប្រកាសនេះ មានគោលដៅដូចតទៅ ៖

- ពង្រឹងការគ្រប់គ្រងការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ឱ្យកាន់តែមានប្រសិទ្ធភាព
- លើកកម្ពស់គុណភាពសេវាកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ និងបង្កើនការទាក់ទាញទេសចរជាតិ និងអន្តរជាតិ។

**ប្រការ ៣._**

បច្ចេកសព្ទដែលប្រើក្នុងប្រកាសនេះ មាននិយមន័យដូចមានចែងក្នុងប្រការនេះ និងនៅក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីទេសចរណ៍ដូចតទៅ ៖

បុគ្គល : សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

ប្រតិបត្តិករទេសចរណ៍: សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីព ឬធ្វើអាជីវកម្មសេវាកម្មទេសចរណ៍។

សាខា : សំដៅដល់ការិយាល័យតំណាងឱ្យការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ដែលធ្វើសកម្មភាពក្នុងដែនកំណត់ដែលមានការយល់ព្រមតាមកិច្ចសន្យា។

ការីទេសចរណ៍ : សំដៅដល់បុគ្គលដែលរៀបចំ និងលក់ខ្សែទស្សនកិច្ច ព្រមទាំងប្រមូលផ្តុំសេវាកម្មទេសចរណ៍ផ្សេងៗទៀតសម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា។

ភ្នាក់ងារទេសចរណ៍ : សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរ ដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀតរាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតឡើងដោយការីទេសចរណ៍ផងដែរ។

**ប្រការ ៤._**

ការីទេសចរណ៍ ត្រូវបានបែងចែកជា ០៣ ប្រភេទដូចតទៅ ៖

- ការីទេសចរណ៍ដែលនាំភ្ញៀវចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវនៅក្រៅប្រទេសចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- ការីទេសចរណ៍ដែលនាំភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា(Outbound Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា
- ការីទេសចរណ៍ដែលនាំភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា(Domestic Tour Operators) សំដៅដល់បុគ្គលដែលទទួលរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ត្រូវបានបែងចែកជា ០៤ប្រភេទដូចតទៅៈ

- អាជ្ញាបណ្ណទេសចរណ៍ ផ្តល់ដល់ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍ ផ្តល់ដល់ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរចូលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍ ផ្តល់ដល់ការីទេសចរណ៍ដែលនាំភ្ញៀវទេសចរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators)
- អាជ្ញាបណ្ណទេសចរណ៍ ផ្តល់ដល់ភ្នាក់ងារទេសចរណ៍ (Travel Agent) ។

**ប្រការ ៥._**

អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលនាំភ្ញៀវទៅកម្សាន្តក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators) និងការីទេសចរណ៍ ដែលនាំភ្ញៀវទេសចរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators) ត្រូវបានអនុញ្ញាតសម្រាប់តែការីទេសចរណ៍ទាំងឡាយណាដែលមានសញ្ជាតិខ្មែរតែប៉ុណ្ណោះ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណទេសចរណ៍

**ប្រការ ៦._**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ និងវាយតម្លៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (រួមទាំងសាខា)។

ការធ្វើប្រតិភូកម្មអំណាចក្នុងការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (រួមទាំងសាខា) ឱ្យមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**ប្រការ ៧._**

គ្មានបុគ្គលណាអាចប្រកបអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (រួមទាំងសាខា)បានដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ដែលផ្តល់ដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្តឡើយ។

## ជំពូកទី៣

## វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដល់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

**ប្រការ ៨._**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ឬបើកសាខាត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្រសួងទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

(តាមរយៈប្រព័ន្ធ Online ទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាងនិងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. វិញ្ញាបនបត្របញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ខ. ប្រាក់តម្កល់ធានាអាជីវកម្មពីធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍

គ. លិខិតបញ្ជាក់ទីស្នាក់ការ ឬកិច្ចសន្យាជួលផ្ទះ

ឃ. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម

ង. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)

ច. រូបថតម្ចាស់អាជ្ញាបណ្ណទេសចរណ៍ (៤x៦) ចំនួន០៣សន្លឹក

**ប្រការ ៩._**

បុគ្គលដែលស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (រួមទាំងសាខា) ត្រូវដាក់ពាក្យស្នើសុំនៅក្រសួងទេសចរណ៍តាមរយៈមន្ទីរទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Online ទទួលស្គាល់ដោយក្រសួងទេសចរណ៍) ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

ក. ប្រាក់តម្កល់ធានាអាជីវកម្មពីធនាគារដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍

ខ. អាជ្ញាបណ្ណទេសចរណ៍ច្បាប់ដើម

គ. របាយការណ៍សកម្មភាពអាជីវកម្មឆ្នាំមុន

ឃ. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ក្នុងការប្រកបអាជីវកម្ម

ង. រូបថតម្ចាស់អាជ្ញាបណ្ណទេសចរណ៍ (៤x៦) ចំនួន០៣សន្លឹក

**ប្រការ ១០._**

លក្ខខណ្ឌ និងបែបបទដើម្បីស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ (ថ្មី បន្ត និងបិទអាជីវកម្ម) ត្រូវបានកែសម្រួល និងបន្ថែមក្នុងករណីដូចខាងក្រោម ៖

ក. ករណីមានការផ្ទេរសិទ្ធិឈរឈ្មោះ ឬប្តូរម្ចាស់អាជ្ញាបណ្ណទេសចរណ៍ អ្នកស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ដែលជាអ្នកទទួលសិទ្ធិឈរឈ្មោះ ឬម្ចាស់អាជ្ញាបណ្ណទេសចរណ៍នោះ ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ ៨ និងប្រការ ៩ ដូចខាងក្រោម៖

១. លិខិតប្រគល់សិទ្ធិ

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកផ្ទេរសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ចាស់ដែលត្រូវប្តូរ)

៣. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់អ្នកទទួលសិទ្ធិ (ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ថ្មី)

ខ. ករណីប្តូរនាមករណ៍ អ្នកស្នើសុំអាជ្ញាបណ្ណការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ត្រូវបំពេញសំណុំបែបបទបន្ថែមលើលក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងប្រការ ៨ និងប្រការ ៩ នូវ ៖

១. លិខិតអនុញ្ញាតឱ្យប្តូរនាមករណ៍ថ្មីដែលចេញដោយក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

២. កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ទទួលខុសត្រូវចំពោះនាមករណ៍ចាស់។

**ប្រការ ១១._**

អាជ្ញាបណ្ណទេសចរណ៍មានសុពលភាពរយៈពេល១ (មួយ)ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណទេសចរណ៍ ដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត។

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ត្រូវដាក់ពាក្យសុំបន្តអាជ្ញាបណ្ណទេសចរណ៍ឱ្យបាន ៣០ (សាមសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃផុតកំណត់នៃសុពលភាពអាជ្ញាបណ្ណទេសចរណ៍ចាស់។

ក្នុងករណីដែលម្ចាស់អាជ្ញាបណ្ណទេសចរណ៍ នៅតែបន្តអាជីវកម្មលើអាជ្ញាបណ្ណដែលអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ ១២._**

នៅពេលអ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍ បានបំពេញបែបបទត្រឹមត្រូវឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍នឹងចេញអាជ្ញាបណ្ណទេសចរណ៍ជូនអ្នកស្នើសុំសម្រាប់ធ្វើអាជីវកម្មជាការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (រួមទាំងសាខា) ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ។

ប្រសិនបើអ្នកស្នើសុំពុំអាចបំពេញតាមបែបបទនិងលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍អាចអនុញ្ញាតឱ្យអ្នកស្នើសុំធ្វើកិច្ចសន្យាបំពេញបន្ថែមនូវលក្ខខណ្ឌ ដែលមិនពេញលេញជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ ក្រសួងទេសចរណ៍នឹងចេញអាជ្ញាបណ្ណបណ្តោះអាសន្នដែលមានសុពលភាពរយៈពេល៩០ (កៅសិប) ថ្ងៃ ក្រោយពេលអ្នកស្នើសុំបានបង់កម្រៃអាជ្ញាបណ្ណទេសចរណ៍រួច។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើម្ចាស់អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នអាចបំពេញតាមលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះ ក្រសួងទេសចរណ៍នឹងផ្តល់អាជ្ញាបណ្ណទេសចរណ៍ពេញសិទ្ធិដល់អ្នកស្នើសុំ។

ផ្ទុយទៅវិញក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញតាមលក្ខណវិនិច្ឆ័យនៃប្រកាសនេះ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ហើយនៅតែបន្តអាជីវកម្មលើអាជ្ញាបណ្ណបណ្តោះអាសន្នដែលអស់សុពលភាពនឹងត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ ១៣._**

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍ច្រើនប្រភេទនៅលើទីតាំងតែមួយ ប្រភេទអាជីវកម្មនីមួយៗត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

បុគ្គលដែលប្រកបអាជីវកម្មទេសចរណ៍មួយប្រភេទ ហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ផ្សេងៗគ្នា។

**ប្រការ ១៤._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍អាចធ្វើការផ្ទេរ ឬលក់អាជ្ញាបណ្ណទេសចរណ៍របស់ខ្លួនបានដោយត្រូវដាក់ពាក្យស្នើសុំមកក្រសួងទេសចរណ៍។ ការផ្ទេរ ឬការលក់អាជ្ញាបណ្ណទេសចរណ៍អាចប្រព្រឹត្តទៅបានដោយគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី២នៃមាត្រា ៤៣នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ ១៥._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ត្រូវប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍នេះ ឱ្យបានត្រឹមត្រូវតាមកម្មវត្ថុនៃអាជីវកម្មរបស់ខ្លួនហើយត្រូវគោរពអនុវត្តតាមការណែនាំនិងបទប្បញ្ញត្តិនានារបស់ក្រសួងទេសចរណ៍និងស្ថាប័នពាក់ព័ន្ធ។

ម្ចាស់អាជ្ញាបណ្ណការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ និងសាខាមិនត្រូវអនុញ្ញាតឱ្យបុគ្គល ឬការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ឬសាខាដទៃប្រើប្រាស់នាមករណ៍អាជ្ញាបណ្ណរបស់ខ្លួនឡើយ។

ម្ចាស់អាជ្ញាបណ្ណការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការឈរឈ្មោះតំណាងឱ្យការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ឬសាខាដទៃក្រៅពីការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ និងសាខារបស់ខ្លួនឡើយ។

អាជ្ញាបណ្ណទេសចរណ៍ត្រូវដាក់តាំងនៅកន្លែងទទួលភ្ញៀវដែលងាយមើលឃើញច្បាស់។ ក្នុងករណីមានការខូចខាត ឬបាត់បង់អាជ្ញាបណ្ណទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចដើម្បីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ទុតិយតាក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃគិតពីថ្ងៃដែលខូចខាត ឬបាត់បង់។

**ប្រការ ១៦._**

ការផ្តល់ ឬការបន្តអាជ្ញាបណ្ណទេសចរណ៍ ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្នឱ្យប្រកបអាជីវកម្មជាការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ឬបើកសាខាជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ និង/ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត។

**ប្រការ ១៧._**

ប្រតិបត្តិករទេសចរណ៍ អាចដាក់ពាក្យស្នើសុំព្យួរអាជ្ញាបណ្ណទេសចរណ៍របស់ខ្លួនជាបណ្តោះអាសន្នក្នុងរយៈពេល១ឆ្នាំ ការស្នើសុំនេះមិនត្រូវលើសពី២ដងដោយមានការយល់ព្រមពីក្រសួងទេសចរណ៍ និង/ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត។

## ជំពូកទី៤

## ប្រាក់តម្កល់ និងតម្លៃអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

**ប្រការ ១៨._**

ប្រាក់តម្កល់ធានាការប្រកបអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ត្រូវបានកំណត់ទៅតាមវិសាលភាព និងទំហំអាជីវកម្មដូចខាងក្រោម៖

ក. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវទៅកម្សាន្តក្រៅប្រទេស (Outbound)ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន ៧.០០០ (ប្រាំពីរពាន់)ដុល្លារអាមេរិក។

ខ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវចូលមកកម្សាន្តក្នុងប្រទេស (Inbound) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

គ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ភ្នាក់ងារទេសចរណ៍ (Travel Agent) ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន ៥.០០០ (ប្រាំពាន់)ដុល្លារអាមេរិក។

ឃ. អាជ្ញាបណ្ណទេសចរណ៍ផ្តល់ដល់ការីទេសចរណ៍ដែលអាចធ្វើអាជីវកម្មរៀបចំខ្សែទស្សនកិច្ចជូនភ្ញៀវដែលមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជាកម្សាន្តក្នុងប្រទេស (Domestic)ត្រូវតម្កល់ប្រាក់ធានាអាជីវកម្មចំនួន ២.០០០ (ពីរពាន់)ដុល្លារអាមេរិក។

❖ ចំពោះប្រតិបត្តិករទេសចរណ៍ ដែលមានអាជ្ញាបណ្ណទេសចរណ៍ជាការីទេសចរណ៍ច្រើនប្រភេទ រួមមានអាជ្ញាបណ្ណជាការីទេសចរណ៍ផង និងភ្នាក់ងារទេសចរណ៍ផង ហើយស្ថិតក្រោមឈ្មោះតែមួយត្រូវតម្កល់ប្រាក់ដូចមានចែងក្នុងប្រការនេះ ក្នុងកម្រិតទឹកប្រាក់ខ្ពស់ជាងគេ។

សាខាមិនតម្រូវឱ្យតម្កល់ប្រាក់ធានាអាជីវកម្មដោយឡែកឡើយក្នុងករណីដែលការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (ស្នាក់ការកណ្តាល)របស់ខ្លួនបានអនុវត្តនីតិវិធីនៃការដាក់ប្រាក់តម្កល់ធានាអាជីវកម្មរួចរាល់ហើយ។

ក្រសួងទេសចរណ៍ទទួលបន្ទុកគ្រប់គ្រងលើប្រាក់តម្កល់ធានាអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។

**ប្រការ ១៩._**

ប្រតិបត្តិករអាចដាក់ពាក្យសុំដកប្រាក់តម្កល់ធានាអាជីវកម្មរបស់ខ្លួនមកវិញបាន នៅពេលបិទអាជីវកម្មជាការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។ ក្នុងករណីនេះ ប្រតិបត្តិករទេសចរណ៍ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ និងធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈជាមុនក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ មុនថ្ងៃបិទអាជីវកម្មរបស់ខ្លួន។

ប្រតិបត្តិករទេសចរណ៍ដែលជាម្ចាស់អាជីវកម្ម ត្រូវធ្វើកិច្ចសន្យាធានា និងទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងករណីមានការពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុជាមួយនឹងដៃគូផ្សេងៗរបស់ខ្លួនកន្លងមក។ ក្រសួងទេសចរណ៍នឹងពិនិត្យសម្រេចអនុញ្ញាតលើការបិទអាជីវកម្មក្នុងរយៈពេលមិនលើសពី២៨ (ម្ភៃប្រាំបី)ថ្ងៃគិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំ។

**ប្រការ ២០._**

ការយកកម្រៃលើការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ឬការអនុញ្ញាតឱ្យបន្តអាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ត្រូវអនុលោមតាមប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍។

## ជំពូកទី៥

## ភារកិច្ចរបស់ប្រតិបត្តិករទេសចរណ៍

**ប្រការ ២១._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានភារកិច្ចដែលមានចែងក្នុងមាត្រា៤៨ នៃច្បាប់ស្តីពីទេសចរណ៍ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ដែលរៀបចំដោយក្រសួងទេសចរណ៍ឬសមាគមឧស្សាហកម្មទេសចរណ៍ ឬអង្គការទេសចរណ៍ពិភពលោកឱ្យបានល្អ។

**ប្រការ ២២._**

ប្រតិបត្តិករទេសចរណ៍ត្រូវមានផែនការ និងមានសកម្មភាពបណ្តុះបណ្តាលនិងហ្វឹកហ្វឺនដល់បុគ្គលិកបម្រើការងារអំពីជំនាញបដិសណ្ឋារកិច្ច ឬគ្រប់គ្រងទេសចរណ៍ស្របតាមការណែនាំរបស់ក្រសួងទេសចរណ៍។

**ប្រការ ២៣._**

ប្រតិបត្តិករទេសចរណ៍ត្រូវផ្តល់របាយការណ៍ និងស្ថិតិពីអាជីវកម្មរបស់ខ្លួនជូនក្រសួងទេសចរណ៍រៀងរាល់៣ខែម្តង និងទៅតាមការស្នើសុំរបស់ក្រសួងទេសចរណ៍។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ ២៤._**

ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (រួមទាំងសាខា) ដែលប្រកបអាជីវកម្មដោយប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ហួសសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា ៦៥នៃច្បាប់ស្តីពីទេសចរណ៍។ ទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍សម្រាប់ការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍ ដូចខាងក្រោម៖

- រយៈពេលក្រោម ០១ (មួយ)ឆ្នាំ គិតចាប់ពីថ្ងៃផុតសុពលភាពនៃ អាជ្ញាបណ្ណទេសចរណ៍ត្រូវពិន័យជាប្រាក់ស្មើនឹង ២.០០០.០០០ (ពីរលាន)រៀល
- ចាប់ពី០១ (មួយ)ឆ្នាំឡើងទៅ គិតចាប់ពីថ្ងៃផុតសុពលភាពនៃ អាជ្ញាបណ្ណទេសចរណ៍ ទំហំទឹកប្រាក់ពិន័យជាទឹកប្រាក់ស្មើនឹង ២.០០០.០០០ (ពីរលាន)រៀល គុណនឹងចំនួនមេគុណឆ្នាំ វិធីសាស្ត្រគណនាមេគុណឆ្នាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ជនណាដែលក្លែងអាជ្ញាបណ្ណការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ២៥._**

ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ដែលហួសសុពលភាព ត្រូវមកបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងរបស់ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត។

ករណី មិនចូលមកបង់ប្រាក់ពិន័យអន្តរការណ៍តាមកាលបរិច្ឆេទកំណត់ខាងលើ ទំហំទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវអនុវត្តជាប្រាក់ទ្វេដង។

ការពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យម្ចាស់អាជីវកម្មរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

**ប្រការ ២៦._**

បុគ្គលដែលប្រកបអាជីវកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (រួមទាំងសាខា) ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង ៥.០០០.០០០ (ប្រាំលាន)រៀល ក្នុងឆ្នាំដំបូង។ ក្នុងករណីក្រសួងរកឃើញថា ការប្រកបអាជីវកម្មនោះ មានរយៈពេលលើសពីមួយឆ្នាំឡើងទៅ ទំហំទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវអនុវត្តគុណនឹងចំនួនមេគុណឆ្នាំ។

ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្តនឹងធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់អាជីវកម្មដែលគ្មានអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ អំពីករណីនៃការពិន័យអន្តរការណ៍នេះ។

**ប្រការ ២៧._**

ក្នុងករណីម្ចាស់អាជ្ញាបណ្ណការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍រំលោភលើកាតព្វកិច្ចដូចមានចែងក្នុងប្រការ២១ ជំពូកទី៥នៃប្រកាសនេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ២.០០០.០០០(ពីរលាន)រៀល និងអតិបរមាមិនលើសពី ១០.០០០.០០០(ដប់លាន)រៀល។

ការពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យម្ចាស់អាជ្ញាបណ្ណទេសចរណ៍រួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ដែលទទួលបានអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវគោរពនិងអនុវត្តឱ្យបានត្រឹមត្រូវស្របតាមប្រភេទអាជីវកម្មដែលបានស្នើសុំ។

ករណីអនុវត្តអាជីវកម្មផ្ទុយនឹងប្រភេទអាជ្ញាបណ្ណទេសចរណ៍ ដែលខ្លួនបានស្នើសុំម្ចាស់អាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង១០.០០០.០០០(ដប់លាន)រៀល។ ការពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យម្ចាស់អាជីវកម្មរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

**ប្រការ ២៨._**

ករណីដែលប្រតិបត្តិករទេសចរណ៍មិនអនុវត្តតាមប្រការដូចមានចែងក្នុងជំពូកទី៥ និងជំពូកទី៦ នៃប្រកាសនេះ ក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្តនឹងអនុវត្តនីតិវិធីតាមផ្លូវតុលាការ។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**ប្រការ ២៩._**

អាជ្ញាបណ្ណទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្តកន្លងមកដែលនៅមានសុពលភាពត្រូវបន្តអនុវត្តរហូតដល់អស់សុពលភាព។

ប្រតិបត្តិករទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មជាការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ឬបន្តអាជ្ញាបណ្ណទេសចរណ៍សម្រាប់ឆ្នាំថ្មីត្រូវអនុវត្តតាមលក្ខខណ្ឌ និងការកំណត់ដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ ៣០._**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣១._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នាយកខុទ្ទកាល័យ គ្រប់ប្រធាននាយកដ្ឋាន អធិការ ក្រុមអ្នកច្បាប់នៃក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី -ខេត្ត និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត «ដើម្បីជូនជ្រាប»
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
- ដូចប្រការ ៣១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ